# ប្រវត្តិវិទ្យា

# អាណានិគមនិយមបារាំង (១៨៦៣-១៩៥៣)

## 1- សន្ធិសញ្ញាថ្ងៃទី 11 សីហា 1863 និងការចូលត្រួតត្រាកម្ពុជា

### 1.1 ស្ថានភាពប្រទេសកម្ពុជា

នៅស.វ ទី 19 ប្រទេសកម្ពុជាស្ថិតនៅក្រោមអំណាចត្រួតត្រា យួន និង សៀម។ នៅក្នុងរាជ្យព្រះបាទអង្គ ឌួង (1841-1860) សៀម និង យួន នៅប្រចាំការអមព្រះអង្គ ដើម្បីសំរេចរាជកិច្ចជំនួសស្តេចខ្មែរ។ ចំពោះទង្វើគាបសង្កត់បែបនេះព្រះអង្គបានរិះរកគ្រប់មធ្យោបាយដើម្បីដោះខ្លួនចេញពី យួន និង សៀម។

នៅឆ្នាំ 1854 ព្រះបាទអង្គ ឌួង បានអោយរាជទូតខ្មែរទៅទាក់ទង នឹង កុងស៊ុល នៅសឹង្ហបូរី ប៉ុន្តែពុំបានសំរេចដូចបំនង ព្រោះសៀម បានដឹងពត៌មាននេះ ហើយបានគំរាមគំហែងដល់ព្រះអង្គ។ ដូចនេះការចុះសន្ធិសញ្ញាបារាំង-ខ្មែរត្រូវបានផ្អាក ហើយ ព្រះអង្គក៏ចូលបានទីវង្គតនៅថ្ងៃទី 19 តុលា 1860។

### 1.2 ស្ថានភាពនយោបាយបារាំង

នៅឆ្នាំ 1862 លោកឧត្តម នាវីត្រីបូណា ទេសាភិបាលនៃដែនដីកូសាំងស៊ីន បានធ្វើដំណើរមកប្រទេសខ្មែរ ហើយត្រូវបានទទួលយ៉ាងរាក់ទាក់ពីព្រះ នរោត្តម។ ទេសាភិបាលរូបនេះយល់ថាប្រទេសបារាំងមានសិទ្ធិលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ ខ្មែរ។

នៅឆ្នាំ 1863 ក្រោយពីធ្វើការដោះដូរទេសាភិបាលថ្មី លោក ឌឺឡាហ្គ្រង់ឌីយ៉ែ បានទូលឲ្យស្តេចខ្មែរ ដើម្បីឲ្យ ព្រះអង្គ ដាក់ ប្រទេសខ្មែរ ឲ្យបារាំងជួយការពារ។ បារាំងបានថ្វាយនូវគម្រោង សន្ធិសញ្ញាមួយ ហើយបាន ចុះហត្ថលេខាដោយលោក ឌឺឡាហ្គ្រង់ឌីយ៉ែរួមនិង ព្រះបាទ នរោត្តម នៅថ្ងៃទី 11 សីហា 1863 ដែលមានអត្ថន័យរួម គឺ ដាក់ខ្មែរក្រោមអាណាព្យាបាលបារាំង។

### 1.3 ចលនាតស៊ូ និង ការត្រួតត្រាបារាំង

- ចលនា អាចារ្យស្វា (1864-1865) ត្រូវគេចាប់ទៅឃុំនៅកោះ អង់ទីកណ្តាលសមុទ្រ
- ចលនា ពោធិ៍កំបោរ (1865-1867) ត្រូវគេកាត់ក្បាលដោតនៅរាជធានីឧត្តុង្គ
- ចលនា ស៊ីវត្ថា (1861-1891) ស្លាប់ដោយជំងឺ
- ចលនា ក្រឡាហោមគង់ (1885-1886) ត្រូវបានស្លាប់
- ចលនា វិស្ណុលោកឈូក (1885-1886) ត្រូវបានស្លាប់

## 2- អនុសញ្ញាថ្ងៃទី 17 មិថុនា 1884 និង ការធ្វើអាណានិគម

នៅថ្ងៃទី 17 មិថុនា 1884 លោក សាលថុមសុន បានចត កប៉ាល់នៅមុខរាជវាំងភ្នំពេញ ហើយបានបង្ខំឲ្យព្រះបាទ នរោត្តម កំពុងផ្ទុំអោយចុះហត្ថលេខាលើអនុសញ្ញាមួយដែលបានដកហូតអំណាចទាំងអស់ពី ព្រះអង្គ។

អនុសញ្ញា នៅថ្ងៃទី 17 មិថុនា 1884 មានអត្ថន័យរួមគឺ ការដាក់ប្រទេសកម្ពុជាក្រោមការគ្រប់គ្រងរបស់បារាំង ហើយព្រះរាជាខ្មែរត្រូវបាត់បង់អំណាចក្នុងការគ្រប់គ្រងប្រទេសស្ទើរទាំងស្រុង។

## បញ្ហាដែនដី កូសាំងស៊ីន

នៅឆ្នាំ 1864 ព្រះបាទ នរោត្តម អមដោយលោក ឌូដាដឺឡាហ្គ្រេ បានយាងទៅជួបលោក ទេសាភិបាល ឌឺឡាហ្គ្រង់ឌីយ៉ែ នៅ ព្រៃនគរ ហើយធ្វើសំណូមពរឲ្យ បារាំងបង្វិលខេត្តទាំងបីមកអោយខ្មែរវិញ គឺ លង់ហោរ មាត់ជ្រូក និង ពាម។ ឯ បារាំងទទួល ពាក្យជាមួយព្រះអង្គហើយ។ តែក្រោយមកបារាំងបានបំភ្លេចពាក្យសន្យាជាមួយព្រះអង្គវិញ។

បារាំងបានធ្វើសកម្មភាពកែប្រែបន្ទាត់ព្រំដែនដែលចំនេញទៅដែនដីកូសាំងស៊ី ជានិច្ច ដោយពុំអើពើ នឹង ការតវ៉ារបស់ស្តេចខ្មែរយើងឡើយ។

ចាប់ពីឆ្នាំ 1893-1914 ប្រទេសខ្មែរបានបាត់បង់ទឹកដីថែមទៀតព្រមទាំងកោះនៅក្នុង សមុទ្រភាគខាងត្បូងដូចជាកោះត្រឡាចជាដើម។ ទីបំផុតដែនដីទាំងនេះត្រូវ បារាំងកាត់ទៅអោយយួនទាំងអស់ (1947-1949) ដែលសព្វថ្ងៃដែនដីទាំងនោះមាន ឈ្មោះថាទឹកដីកម្ពុជាក្រោម។